# ពុទ្ធប្រវត្ត ( សង្ខេប )

ដើម្បី រំលឹកបុណ្យ វិសាខបូជា ដែលប្រព្រឹត្តទៅ មួយឆ្នាំម្តងៗ នៅថ្ងៃ ១៥ កើត ពេញបូណ៌មី ខែពិសាខ ខ្ញុំ សូមជូនដោយសង្ខេប នូវ ពុទ្ធប្រវត្ត ដូចតទៅនេះ។

ជាដំបូង ព្រះពុទ្ធនៃយើង ព្រះអង្គ ប្រសូត ត្រាស់ដឹង និង បរិនិព្វាន នៅថ្ងៃ ១៥ កើតពេញបូណ៌មី ខែ ពិសាខ ទាំងអស់។ គ្រាន់តែ ឈ្មោះ ថ្ងៃនិងឆ្នាំ ខុសគ្នាតែប៉ុណ្ណោះ។

## ប្រសូត

ព្រះអង្គ ប្រសូត នៅ ថ្ងៃសុក្រ ១៥កើតពេញបូណ៌មី ខែពិសាខ ឆ្នាំច មុន ព.ស. ៨០ឆ្នាំ វេលាថ្ងៃជិតត្រង់ នៅក្នុងព្រៃលុំម្ពិនី ចំកណ្តាលព្រំប្រទល់ដែន នៃប្រទេស កបិលព័ស្តុនគរ ទេវទហៈ ។

## ត្រាស់ដឹង

ព្រះអង្គ ត្រាស់ដឹង នៅ ថ្ងៃពុធ ១៥កើតពេញបូណ៌មី ខែពិសាខ ឆ្នាំរកា មុន ព.ស.៤៥ឆ្នាំ។ ព្រះសិទ្ធត្ថ គង់ក្រោមដើមពោធិ បែរព្រះភក្ត្រមកខាងកើត លើរតនបល្ល័ង្គ ពិចារណា សាចុះ សាឡើង តាមវិធីថ្មីពីរ គឺ បដិលោម ដំណើរច្រាសមកវិញ និង អនុលោម ជាដំណើរតាមបណ្តោយ។

ដោយអានុភាពនៃការពិចារណា សាចុះសាឡើងនេះ ព្រះពោធិសត្វទ្រង់បានញាណបី គឺ

១- ក្នុង បឋមយាម នៃរាត្រី ថ្ងៃពុធ ១៥កើត ខែពិសាខ ឆ្នាំរកា ទ្រង់បាននូវ **បុព្វេនិវាសានុស្សតិញ្ញាណ** គឺការរលឹកឃើញ ជាតិកំណើត តាំងពីជាតិត្រាស់ដឹងជាព្រះពុទ្ធ រហូតដល់ អនេកជាតិ ។

២- ដល់ មជ្ឈិមយាម ទ្រង់ពិចារណានូវនិស្ស័យរបស់សត្វ ទ្រង់ក៏បានឃើញ ការច្យុត និង កើត របស់សត្វលោក ទ្រង់ក៏បានសម្រេចញាណទី២ គឺ **ចុតូបបាតញ្ញាណ** គឺ ដឹងនូវ

*ការកើត និងការស្លាប់ ព្រមទាំងកម្មផល របស់សត្វលោក ដោយឥតទើសទាល់។*

*៣- ដល់ បច្ឆិមយាម ទ្រង់លើកយក* **បដិច្ចសមុប្បាទធម៌១២** *មកពិចារណា សាចុះសាឡើង ព្រះអង្គក៏បានទទួលនូវញាណទី៣ ហៅថា* **អាសវក្ខយញ្ញាណ** *គឺការដឹង នូវហេតុផល នៃការកើត និងរលត់ នៃ អាសវក្ខ គឺ គ្រឿង សៅហ្មង ។*

## បរិនិព្វាន

*ព្រះអង្គ ចូលបរិនិព្វាន នៅ ថ្ងៃ អង្គារ ១៥កើតពេញបូណ៌មី ខែពិសាខ ឆ្នាំម្សាញ់ វេលាជិតភ្លឺ ក្នុងព្រះជន្មាយុ ៨០ ព្រះវស្សា ដែលជាថ្ងៃចាប់ផ្តើមនៃពុទ្ធសករាជ។ ហើយគេកំណត់យកថ្ងៃ ១រោជខែវិសាខ ឆ្នាំម្សាញ់នោះ ជាថ្ងៃទី ១ នៃ ពុទ្ធសករាជ ៕*